# [មជ្ឈមណ្ឌលសិទ្ធិមនុស្សព្រួយបារម្ភពីការកើនឡើង នៃការបង្ខំអោយជនសង្ស័យសារភាព]

Written by កែវ វតន: Friday, 24 June 2011 10:52

There are no translations available.

មជ្ឈ មណ្ឌលសិទ្ធិមនុស្សកម្ពុជា រកឃើញថា កំណើននៃការធ្វើទារុណកម្មទៅលើជនសង្ស័យ ដើម្បីទទួលបានចំលើយសារភាព ដែលប្រព្រឹត្តិដោយនគរបាលយុត្តិធម៌ នៅតែកើនឡើង បើទោះមានការព្យាយាម អោយមានភាពប្រសើរលើប្រព័ន្ធយុត្តិធម៌ក៏ដោយនោះ។

នៅក្នុងកម្រងឯកសារវិភាគស្តី ពីសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌និងនិតិរដ្ឋ ដែលធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ហើយបានចេញផ្សាយនៅថ្ងៃនេះ បានអោយដឹងថា មានជនជាប់ចោទជាច្រើន អះអាងថា នគរបាលបានបង្ខំនិងប្រើអំពើហិង្សាលើពួកគេ ដើម្បីបានចំលើយធ្វើជាកំនត់ហេតុ ក្នុងការដាក់បន្ទុកពីបទចោទព្រហ្មទណ្ឌ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានរកឃើញថា នៅរយៈពេល ៦ខែចុងក្រោយនៃសវនាការចំនួន៥៨៥ មានជនសង្ស័យចំនួន៧% បានអះអាងថា មន្ត្រីនគរបាលយុត្តិធម៌បានបង្ខំ និងប្រើអំពើហិង្សាសួរចំលើយពួកគេ។

មន្ត្រីសង្កេតការណ៍សវនាការនៃមជ្ឈ មណ្ឌលសិទ្ធិមនុស្សកម្ពុជា កញ្ញា ម៉ាំង មូនីកា មានប្រសាសន៍ថា ករណីនេះបានរកឃើញនៅតុលាការខេត្តកណ្តាល និងសាលាដំបូង រាជធានីភ្នំពេញ។ កញ្ញាបន្តថា ករណីដែលមន្ត្រីនគរបាលបង្ខំ និងប្រើអំពើហឹង្សាលើជនសង្ស័យនេះ នៅតែកើនឡើងជាបន្តបន្ទាប់ *៖” អ្វីដែលយើងលើកទិន្នន័យមក នេះមិនបានរកឃើញថា ប៉ូលិសបង្ខំជនជាប់ចោទទេ គឺយើងទៅសង្កេតមើលក្នុងតុលាការ ស្តាប់ការអះអាងរបស់ជនជាប់ចោទ ថាប៉ូលិសបានបង្ខិតបង្ខំ ឬប្រើអំពើហឹង្សាលើពួកគាត់។ យើងមិនដឹងថាការអះអាងរបស់គាត់ត្រឹមត្រូវឬយ៉ាងណាទេ?” ។*

នៅរសៀលថ្ងៃសុក្រនេះ VOD ពុំអាចសុំការបំភ្លឺពីមន្ត្រីពន្ធនាគារព្រៃសរ និងខេត្តកណ្តាល ចំពោះករណីនេះបានទេ។

យោងតាមក្រមនិតិវិធីព្រហ្មទណ្ឌមាត្រា ៣២១ បានកំណត់ថា រាល់ភស្តុតាងដែលបានមកពីបង្ខិតបង្ខំរូបកាយ ឬខាងផ្លូវចិត្ត មិនអាចយកជាការបានទេ។ ជាមួយគ្នានេះមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញចែងថា ច្បាប់ធានាការ៉ប់រងមិនអោយមានការរំលោភលើរូបកាយ បុគ្គលណាមួយឡើយ។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបកាយ ឬប្រព្រឹត្តកម្មណាមួយ ដែលបន្ថែមទម្ងន់ទោសទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់៕